# ថ្នាំបង្ការជំងឺ COVID-19 - សំណួរដែលបានសួរជាញឹកញាប់ ដូសជំរុញ

ដើម្បីមើលសំណួរទាំងនេះ និងសំណួរដែលបានសួរជាញឹកញាប់ផ្សេងទៀតទាក់ទងនឹងថ្នាំបង្ការ តាមអនឡាញ សូមចូលទៅកាន់ គេហទំព័រអំពីថ្នាំបង្ការជំងឺ COVID-19។

## តើបុគ្គលណាខ្លះដែលត្រូវបានណែនាំឱ្យមកទទួលចាក់ដូសជំរុញនៃថ្នាំបង្ការជំងឺ COVID-19?

មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) ណែនាំឱ្យមនុស្សគ្រប់រូបដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ ទទួលចាក់ដូសជំរុញ សម្រាប់ប្រព័ន្ធការពារដ៏ល្អបំផុតប្រឆាំងនឹងជំងឺ COVID-19។ លើសពីនេះទៅទៀត មនុស្សមួយចំនួនដែលប្រឈមនឹងហានិភ័យខ្ពស់ជាងមុន អាចជ្រើសរើសទទួលចាក់ដូសជំរុញលើកទី 2 បាន។ (សូមមើលសំណួរ *តើបុគ្គលណាដែលអាចទទួលចាក់ដូសជំរុញលើកទី 2 បាន?* នៅខាងក្រោម)។ ដូសជំរុញទាំងឡាយមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ចំពោះកុមារដែលមានអាយុចាប់ពី 5 ទៅ 11 ឆ្នាំ នាពេលបច្ចុប្បន្ននេះឡើយ។

ការទទួលចាក់ដូសជំរុញនៃថ្នាំបង្ការជំងឺ COVID-19 គឺមានសារៈសំខាន់ ពីព្រោះវាជួយពង្រឹងភាពស៊ាំរបស់អ្នក។ កត្តានេះផ្តល់នូវប្រព័ន្ធការពារប្រសើរជាងមុនដល់អ្នក ពីការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ការត្រូវសម្រាកព្យាបាលមន្ទីរពេទ្យ និងសូម្បីតែការស្លាប់ផងដែរ។

## តើខ្ញុំមានសិទ្ធិអាចទទួលចាក់ដូសជំរុញបាននៅពេលណា?

- ប្រសិនបើអ្នកមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ អ្នកមានសិទ្ធិអាចទទួលចាក់ដូសជំរុញបាន៖
    - ក្នុងរយៈពេល 2 ខែបន្ទាប់ពីបានទទួលចាក់ថ្នាំបង្ការប្រភេទ J&J តែមួយដូស ឬ
    - ក្នុងរយៈពេល 5 ខែបន្ទាប់ពីបានទទួលចាក់ដូសទី 2 នៃថ្នាំបង្ការប្រភេទ Moderna ឬប្រភេទ Pfizer។

  ដូសជំរុញអាចជាថ្នាំបង្ការជំងឺ COVID-19 ប្រភេទណាមួយក៏បាន ប៉ុន្តែពេញចិត្តឱ្យទទួលចាក់ថ្នាំបង្ការប្រភេទ Pfizer ឬប្រភេទ Moderna ជាង។ កុមារដែលមានអាយុចាប់ពី 12 ទៅ 17 ឆ្នាំអាចទទួលចាក់បានតែថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer ប៉ុណ្ណោះ។
- ប្រសិនបើអ្នកមានប្រព័ន្ធភាពស៊ាំចុះខ្សោយកម្រិតមធ្យមឬធ្ងន់ធ្ងរ អ្នកគួរតែទទួលចាក់ដូសជំរុញរបស់អ្នកឱ្យបានឆាប់ជាងមុន។ សូមមើលគេហទំព័រ ថ្នាំបង្ការជំងឺ COVID-19 សម្រាប់បុគ្គលដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយកម្រិតមធ្យមឬធ្ងន់ធ្ងរ របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) ដើម្បីស្វែងយល់បន្ថែម ។
- ប្រសិនបើអ្នកបានទទួលចាក់លំដាប់ថ្នាំបង្ការនៅក្រៅសហរដ្ឋអាមេរិក សូមមើលគេហទំព័រ ថ្នាំបង្ការជំងឺ COVID-19 សម្រាប់អ្នកដែលបានទទួលចាក់ថ្នាំបង្ការនៅខាងក្រៅសហរដ្ឋអាមេរិក របស់ CDC ដើម្បីដឹងថាតើអ្នកមានសិទ្ធិអាចទទួលចាក់ដូសជំរុញបាននៅពេលណា។

## តើបុគ្គលណាដែលអាចទទួលចាក់ដូសជំរុញលើកទីពីរបាន?

បុគ្គលដូចខាងក្រោមនេះមានសិទ្ធិអាចទទួលចាក់ដូសជំរុញនៃថ្នាំបង្ការជំងឺជំងឺ COVID-19 លើកទី 2 បាន *ប្រសិនបើមានរយៈពេលយ៉ាងហោចណាស់ 4 ខែ* ចាប់តាំងការទទួលចាក់ដូសជំរុញលើកទី 1 របស់ពួកគេ៖

- មានអាយុចាប់ពី 50 ឆ្នាំឡើងទៅ
- មានអាយុចាប់ពី 18 ទៅ 49 ឆ្នាំ និងបានទទួលចាក់ថ្នាំបង្ការប្រភេទ J&J ដូសដំបូង *ហើយនិង* ដូសជំរុញប្រភេទ J&J។
- មានអាយុចាប់ពី 12 ឆ្នាំឡើងទៅ និង មានប្រព័ន្ធភាពស៊ាំចុះខ្សោយកម្រិតមធ្យមឬធ្ងន់ធ្ងរ

សូមសាកសួរគ្រូពេទ្យរបស់អ្នក ប្រសិនបើអ្នកមានសំណួរ ថាតើអ្នកគួរតែទទួលចាក់ដូសជំរុញលើកទីពីរឬទេនោះ។

## តើខ្ញុំគួរទទួលចាក់ដូសជំរុញលើកទីពីរនៅពេលណា?

ប្រសិនបើអ្នកស្ថិតនៅក្នុងក្រុមមួយក្នុងចំណោមក្រុមនានាដែលអាចទទួលចាក់ដូសជំរុញលើកទី 2 បាននោះ អ្នកអាចជ្រើសរើសទទួលចាក់ថ្នាំបង្ការនៅពេលនេះ ឬរង់ចាំក៏បាន។ ចូរពិចារណាអំពីស្ថានភាពរបស់អ្នក ព្រមទាំងហានិភ័យនិងអត្ថប្រយោជន៍ផ្សេងៗ។ គ្រូពេទ្យរបស់អ្នកអាចជួយអ្នកក្នុងការពិនិត្យមើលជម្រើសទាំងឡាយរបស់អ្នក។ អ្នកមិនត្រូវការដូសជំរុញលើកទី 2 ដើម្បីត្រូវបានចាត់ទុកថាថ្នាំបង្ការជំងឺ COVID-19 របស់អ្នក គ្រប់លក្ខណៈនិងទាន់ពេលវេលា នៅពេលនេះឡើយ។

កត្តាជាក់លាក់មួយចំនួនអាចធ្វើឱ្យអ្នកទំនងជាអាចធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារជំងឺ COVID-19 បាន។ ប្រសិន

បើអ្នកមានសិទ្ធិអាចទទួលចាក់ដូសជំរុញលើកទីពីរបាន វាអាចមានប្រយោជន៍ក្នុងការទទួលចាក់វានាពេល *ឥឡូវនេះ* ប្រសិនបើអ្នក (ឬប្រសិនបើនរណាម្នាក់ដែលអ្នករស់នៅជាមួយ)៖

- មានប្រព័ន្ធភាពស៊ាំចុះខ្សោយកម្រិតមធ្យម ឬធ្ងន់ធ្ងរ
- ទំនងជាអាចធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារជំងឺ COVID-19 ជាងមុន
- ទំនងជាអាចប៉ះពាល់ទៅនឹងជំងឺ COVID-19 តាមរយៈការងាររបស់អ្នក ទីកន្លែងដែលអ្នករស់នៅ ឬកត្តាផ្សេងទៀត (ដូចជាការធ្វើដំណើរញឹកញាប់ ឬការចូលរួមក្នុងការជួបជុំធំៗជាដើម) ជាងមុន
- ស្ថិតនៅក្នុងតំបន់មួយដែលមានកម្រិតចម្លងនៃជំងឺ COVID-19 ខ្ពស់
- ប្រសិនបើនរណាម្នាក់ដែលអ្នករស់នៅជាមួយ មិនបានទទួលចាក់ថ្នាំបង្ការ

អ្នកអាចពិចារណា *រង់ចាំ* ទទួលចាក់ដូសជំរុញលើកទី 2 ប្រសិនបើអ្នក៖

- ធ្លាប់មានជំងឺ COVID-19 ក្នុងអំឡុងពេល 3 ខែកន្លងមកនេះ
- មានសុខភាពល្អ និងមានកម្រិតការប៉ះពាល់ទៅនឹងអ្នកដទៃតិចតួច

សូមមើលគេហទំព័រអំពី ការទទួលចាក់ដូសជំរុញនៃថ្នាំបង្ការជំងឺ COVID-19 លើកទី 2 របស់មជ្ឈមណ្ឌលគ្រប់គ្រង និងទប់ស្កាត់ជំងឺឆ្លង (CDC) សម្រាប់ព័ត៌មានបន្ថែម។ ចូរពិគ្រោះជាមួយគ្រូពេទ្យរបស់អ្នក ប្រសិនបើអ្នកមានសំណួរនានា។

## តើមានហានិភ័យអ្វីខ្លះចំពោះការចាក់ដូសជំរុញ?

ប្រតិកម្មផ្សេងៗបន្ទាប់ពីទទួលចាក់ដូសជំរុញ គឺដូចជាក្រោយការចាក់ថ្នាំបង្ការដូសដំបូងផងដែរ។ ផលប៉ះពាល់ភាគច្រើន គឺមានកម្រិតស្រាលទៅមធ្យម ហើយមានរយៈពេល 2 ថ្ងៃ ឬតិចជាងនេះ។ ដូចគ្នាទៅនឹងលំដាប់ដំបូងដែរនោះ ផលប៉ះពាល់កម្រិតធ្ងន់ធ្ងរ គឺកម្រនឹងកើតមាន។ សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់គេហទំព័រ ស្តីពី សុវត្ថិភាពនៃថ្នាំបង្ការជំងឺ COVID-19 របស់មជ្ឈមណ្ឌលគ្រប់គ្រង និងទប់ស្កាត់ជំងឺឆ្លង (CDC)។ អត្ថប្រយោជន៍នៃការចាក់ដូសជំរុញ គឺមានច្រើនជាងហានិភ័យដែលបានដឹងនិងទំនងជាកើតមាន។

## តើខ្ញុំនឹងចាំបាច់ត្រូវបង្ហាញកំណត់ត្រា ឬវេជ្ជបញ្ជារបស់គ្រូពេទ្យដើម្បីទទួលចាក់ដូសជំរុញដែរឬទេ?

ទេ អ្នកមិនត្រូវការកំណត់ត្រា ឬវេជ្ជបញ្ជារបស់គ្រូពេទ្យដើម្បីទទួលចាក់ដូសជំរុញទេ។ អ្នកអាចអះអាងដោយខ្លួនឯង (រាយការណ៍ដោយខ្លួនឯង) ប្រសិនបើអ្នកមានសិទ្ធិអាចទទួល។ នៅពេលអ្នកធ្វើដំណើរទៅទីតាំងនេះ សូមនាំយកភ័ស្តុតាងនៃការចាក់ថ្នាំបង្ការដូចជាកាតពណ៌ស របស់អ្នកដែលបានផ្តល់ជូនដោយមជ្ឈមណ្ឌលគ្រប់គ្រង និងទប់ស្កាត់ជំងឺឆ្លង (CDC) ឬកំណត់ត្រានៃការចាក់ថ្នាំបង្ការលក្ខណ:ឌីជីថលទៅជាមួយ។ សូមចូលទៅកាន់គេហទំព័រ វិធីទទួលចាក់ថ្នាំបង្ការ របស់សុខភាពសាធារណ: (Public Health) ដើម្បីទទួលបានព័ត៌មានបន្ថែម។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមនៅទីណា?

- ដើម្បីបោះពុម្ព ឬមើលសំណួរដែលបានសួរញឹកញាប់ទាំងនេះ ឬសំណួរដែលបានសួរជាញឹកញាប់ផ្សេងទៀត ទាក់ទងនឹងប្រធានបទថ្នាំបង្ការជំងឺ COVID-19 សូមស្កេនកូដ QR នេះ ឬចូលទៅកាន់គេហទំព័រ សំណួរដែលបានសួរជាញឹកញាប់ទាក់ទងនឹងថ្នាំបង្ការជំងឺ COVID-19។
- គេហទំព័រ ដូសជំរុញនៃថ្នាំបង្ការជំងឺ COVID-19 របស់មជ្ឈមណ្ឌលគ្រប់គ្រង និងទប់ស្កាត់ជំងឺឆ្លង (CDC)
- គេហទំព័រ VaccinateLACounty.com - រួមទាំងគេហទំព័រ កាលវិភាគនៃការចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលមានរូបភាពក្រាហ្វិចដើម្បីបង្ហាញនូវពេលណាដែលដូសនីមួយៗដល់ពេលកំណត់អាចទទួល និងព័ត៌មានស្តីពី វិធីទទួលចាក់ថ្នាំបង្ការ។
- ចូរពិគ្រោះជាមួយគ្រូពេទ្យរបស់អ្នក ប្រសិនបើអ្នកមានសំណួរផ្សេងៗ។